# ច្បាប់

# ស្តីពី

# ឃតុកម្ម

រដ្ឋសភា
********

# រ ដ្ឋ ក ម្ពុ ជា

## ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

********

# ច្បា ប់

## ស្តីពី

## បា តុ ក ម្ម

****

**មាត្រា ១ :** ការប្រជុំជាពួក ជាកង និងការប្រមូលផ្តុំគ្នាធ្វើបាតុកម្មអាចប្រព្រឹត្តទៅបាន ។ ប៉ុន្តែការប្រជុំជាពួក ជាកងនៅទីកន្លែងសាធារណៈ ឬនៅលើផ្លូវសាធារណៈ ឬការប្រមូលគ្នាដើរតាមផ្លូវជាបាតុកម្ម ដែលអាចបង្កឱ្យខូចភាពសុខសាន្ត ខូចសណ្តាប់ធ្នាប់ ឬសន្តិសុខសាធារណៈ ត្រូវហាមឃាត់ដាច់ខាត ។

**មាត្រា ២ :** ការប្រមូលផ្តុំគ្នាដើរតាមផ្លូវសាធារណៈជាបាតុកម្មសម្តែងមតិលើបញ្ហាអ្វីមួយនិងអាចប្រព្រឹត្តទៅបានតែក្នុងលក្ខខ័ណ្ឌដូចខាងក្រោម ៖

១_ ឥតប្រើហិង្សា ឥតមានកាន់អាវុធ ឬឧបករណ៍ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ។

២_ ឥតបង្កឱ្យខូចភាពសុខសាន្ត សណ្តាប់ធ្នាប់ ឬសន្តិសុខសាធារណៈ ។

៣_ ត្រូវជំរាបជាលាយលក្សណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់នីមួយៗ ដែលបាតុកម្មត្រូវឆ្លងកាត់យ៉ាងតិច ៣ ថ្ងៃមុន ដោយមានចុះនាមត្រកូល នាមខ្លួន អាស័យដ្ឋាន និងហត្ថលេខានៃអ្នករៀបចំបាតុកម្ម ៣ នាក់ ព្រមទាំងបញ្ជាក់គោលបំណងនៃបាតុកម្ម ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការប្រជុំ ផ្លូវ និងចំនួនមនុស្សដែលត្រូវដង្ហែក្បួនបាតុកម្ម ។

បើបាតុកម្មធ្វើនៅទីរួមខេត្ត ឬនៅរដ្ឋធានី ត្រូវជំរាបជាលាយលក្សណ៍អក្សរទៅអាជ្ញាធរទីរួមខេត្ត ឬ អាជ្ញាធររដ្ឋធានី ។

**មាត្រា ៣ :** អាជ្ញាធរដែលបានទទួលលិខិតជូនដំណឹង ត្រូវចេញបង្កាន់ដៃមួយឱ្យ ។

បើអាជ្ញាធរសាមីយល់ឃើញថាបាតុកម្មមានលក្ខណៈដែលអាចនាំឱ្យកើតមានចលាចល នោះអាជ្ញាធរសាមីអាចហាមឃាត់បាតុកម្មដោយចេញសេចក្តីសំរេចមួយក្នុងរយៈពេល ៤៨ ម៉ោង ហើយឱ្យដំណឹងអំពីសេចក្តីសំរេចនោះដល់អ្នករៀបចំបាតុកម្មវិញភ្លាម ។

សេចក្តីចម្លងមួយច្បាប់នៃសេចក្តីសំរេចនោះ ត្រូវធ្វើជូនថ្នាក់លើជ្រាបក្នុងរយៈពេល ២៤ ម៉ោង ។

ក្នុងករណីមិនសុខចិត្ត អ្នករៀបចំបាតុកម្មអាចធ្វើបណ្តឹងតវ៉ាទៅអាជ្ញាធរថ្នាក់លើ ។

អាជ្ញាធរថ្នាក់លើត្រូវសំរេចលើពាក្យតវ៉ានេះថា ឱ្យ ឬ មិនឱ្យ ហើយឱ្យដំណឹងអំពីសេចក្តីសំរេចរបស់ខ្លួននេះដល់ម្ចាស់បណ្តឹងភ្លាម ក្នុងរយៈពេល ២៤ ម៉ោង ។

**មាត្រា ៤ :** កាលបើមានបាតុកម្មកើតឡើងដោយមិនបានជំរាបអាជ្ញាធរមូលដ្ឋានជាមុន ឬដោយអាជ្ញាធរមូលដ្ឋានមិនបានអនុញ្ញាត អាជ្ញាធរមូលដ្ឋានអាចចាត់វិធានការណ៍ឃាត់បាតុករដល់ទីកន្លែង ។

បើក្រោយពីបានដាក់កំហិតឱ្យឈប់ពីរដងហើយ បាតុករនៅតែរឹងរូស មិនព្រមបញ្ឈប់សកម្មភាពរបស់ខ្លួន អាជ្ញាធរមូលដ្ឋានត្រូវចាត់វិធានការណ៍បំបែកហ្វូងបាតុករ ដោយប្រើឧបករណ៍គ្មានគ្រោះថ្នាក់ដល់អាយុជីវិត ។

មាត្រា ៥ : ក្នុងករណីបាតុករមានកាន់អាវុធ ឬឧបករណ៍ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ នោះកងកម្លាំងរក្សាសន្តិសុខមានសិទ្ធិដកហូតអាវុធ និងឧបករណ៍ទាំងនោះ ។ បើបាតុករណ៍រឹងរូសមិនព្រមប្រគល់អាវុធ និងឧបករណ៍ទាំងនោះទេ កងកម្លាំងរក្សាសន្តិសុខមានសិទ្ធិឃាត់ខ្លួនបាតុករ និងដកហូតអាវុធ និងឧបករណ៍ជាបណ្តោះអាសន្ន ។

លុះដល់បាតុកម្មបានស្ងប់ស្ងាត់វិញហើយ ត្រូវដោះលែងជនឃាត់ខ្លួន ព្រមទាំងប្រគល់អាវុធ ឬ ឧបករណ៍ឱ្យសាម៉ីខ្លួនវិញ លើកលែងតែមានបទល្មើសអ្វីផ្សេងទៀត ។

មាត្រា ៦ : ក្នុងករណីបាតុកម្មដោយសន្តិវិធី ក្លាយទៅជាបាតុកម្មហិង្សា ឬ កុបកម្ម អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការយ៉ាងសមស្របបំផុត ដើម្បីបញ្ឈប់បាតុកម្ម ឬ កុបកម្មនោះ ។

វិធានការដែលមានចែងក្នុងមាត្រា ៤ ត្រូវយកមកអនុវត្តជាបឋម ។

មាត្រា ៧ : បាតុករណាដែលប្រើហិង្សាបណ្តាលឱ្យអន្តរាយដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬទ្រព្យសម្បត្តិសាធារណៈ ឬ បណ្តាលឱ្យមានរបួសស្នាម ឬ បាត់បង់អាយុជីវិតអ្នកដទៃ ឬ ភ្នាក់ងាររដ្ឋការកំពុងបំពេញបេសកកម្មត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ដោយយោលទៅតាមកំរិតធ្ងន់ ឬ ស្រាលនៃបទល្មើសដែលបានប្រព្រឹត្ត ។

អ្នកក្លែងបន្លំអុជអាល ញុះញង់ឱ្យប្រើហិង្សា ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមានដូចខាងលើនេះដែរ ។

មាត្រា ៨ : ភ្នាក់ងាររដ្ឋការដែលកំពុងបំពេញភារកិច្ចនៅពេលបាតុកម្ម ហើយបានប្រព្រឹត្តអំពើខុសច្បាប់បណ្តាលឱ្យអន្តរាយដល់ទ្រព្យសម្បត្តិរបស់ប្រជាជន ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ បណ្តាលឱ្យមានរបួសស្នាម ឬ បាត់បង់អាយុជីវិតអ្នកដទៃ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមានដោយយោលទៅតាមកំរិតធ្ងន់ ឬ ស្រាលនៃបទល្មើសដែលបានប្រព្រឹត្ត ។

មាត្រា ៩ : ជនណាដែលឆ្លៀតយកឱកាសបាតុកម្ម ដើម្បីប្រព្រឹត្តអំពើលួច ឆក់ ប្លន់ ឬអំពើល្មើសផ្សេងទៀត ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ដោយយកអតិបរមានៃទោសមកអនុវត្ត ។

មាត្រា ១០ : ការជួសជុលការខូចខាតទាំងឡាយដែលបណ្តាលមកពីបាតុកម្ម ត្រូវជាបន្ទុករបស់ថវិកាខេត្ត ឬ ថវិកាក្រុងសាម៉ី ។ បើការខូចខាតនេះបណ្តាលមកពីកំហុស ឬការធ្វេសប្រហែសរបស់ជនរងគ្រោះ នោះការជួសជុលនៃការខូចខាតត្រូវបន្ថយ ឬបាត់ទាំងស្រុង ។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញបទល្មើស អាជ្ញាធរខេត្ត ក្រុង អាចប្តឹងបកឱ្យជនល្មើសនោះសងថ្លៃជួសជុលការខូចខាតខាងលើនេះមកថវិកាខេត្ត ក្រុងវិញ ។

មាត្រា ១១ : ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

---

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជាអនុម័តនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ នាសម័យប្រជុំវិសាមញ្ញ នៃនីតិកាលទី ១ ។

ភ្នំពេញ. ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១

ជ. រ ដ្ឋ ស ភា

ប្រធាន

ហត្ថលេខា និងត្រា : ជា ស៊ីម

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

អគ្គលេខាធិការ ក្រុមប្រឹក្សារដ្ឋ

ហត្ថលេខា និងត្រា : ចាន់ វ៉ែន